# ១. ចំការឈើជាលក្ខណៈឯកប្រភេទ

## ១.១ យុត្តិកម្ម

ការដាំឈើជាទ្រង់ទ្រាយធំ មានលក្ខណៈសមស្របសំរាប់តំបន់ទាំងឡាយណាដែលគ្មានព្រៃឈើ ឬក៏នៅក្នុងតំបន់ដែលព្រៃឈើរេចរិលខ្លាំង ដែលមិនអាចអនុញ្ញាតឱ្យមានការស្តារព្រៃឈើឡើងវិញកើត។

ក្នុងទស្សនៈនៃការងារដាំដើមឈើ ភាគច្រើនគេនិយមប្រើប្រាស់ប្រភេទឈើតែមួយប្រភេទ ។ ដោយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើប្រាក់ចំណូលដែលបានមកពីពាណិជ្ជកម្មឈើ ជារឿយៗគេនិយមប្រើប្រាស់ប្រភេទឈើនាំចូលជាច្រើនប្រភេទដែលដុះលូតលាស់លឿន (Appanah, 2003)។

ចំការឈើដែលមានតែមួយប្រភេទ មានភាពទាក់ទាញដោយហេតុថាដើមឈើត្រូវបានដាំក្នុងកំរិតដង់ស៊ីតេមួយខ្ពស់ នៅក្នុងតំបន់ដែលងាយស្រួលចេញចូល និងងាយស្រួលក្នុងការគ្រប់គ្រង។ នៅក្នុងអតីតកាល ប្រភេទឈើដែលដុះលូតលាស់លឿនត្រូវបាននិយមប្រើប្រាស់ ដោយសារប្រភេទទាំងនេះមានការកើនមាឌរហ័ស ហើយជាលទ្ធផលធ្វើឱ្យខួបរិលជុំមានរយៈពេលខ្លី។ ក៏ប៉ុន្តែនៅពេលបច្ចុប្បន្ននេះ តំលៃសេដ្ឋកិច្ចនៃប្រភេទឈើនាំចូលដែលដុះលូតលាស់លឿនទាំងនោះកំពុងមានបញ្ហា ហើយលទ្ធភាពនៃការប្រើប្រាស់ប្រភេទឈើក្នុងស្រុកដែលដុះលូតលាស់យឺត ប៉ុន្តែមានតំលៃសេដ្ឋកិច្ចខ្ពស់បាននិងកំពុងមានការទាកក់ទាញយ៉ាងខ្លាំង ជាពិសេសសំរាប់គោលបំណងធ្វើពាណិជ្ជកម្ម និងបរិស្ថាន។ ក្រៅពីមានតំលៃទីផ្សារខ្ពស់ ជាទូទៅប្រភេទឈើក្នុងស្រុក ផ្តល់នូវតំលៃបន្ថែមខាងផ្នែកអេកូឡូស៊ី ដូចជាមានលក្ខណៈបន្សាំទៅនឹងលក្ខខណ្ឌនៃទីកន្លែង និងមានលក្ខណៈទាក់ទាញពពួកសត្វព្រៃ។

ផលប្រយោជន៍ខាងផ្នែកអេកូឡូស៊ីនៃចំការឈើដែលមានតែមួយប្រភេទ អាចនឹងកែលំអឡើងវិញតាមរបៀបពីរ ។ ទីមួយ តាមរយៈការប្រើប្រាស់តំបន់ទ្រនាប់ដែលមានដំណុះរុក្ខជាតិដោយធម្មជាតិនៅតាមបណ្តោយផ្លូវទឹក ដើម្បីការពារការហូរច្រោះ។ ស្រដៀងគ្នានេះដែរ តំបន់ទ្រនាប់ទាំងនោះអាចនឹងត្រូវបង្កើតឡើងដើម្បីខ័ណ្ឌចែកចំការឈើជាអនុតំបន់ ហើយអាចមានតួនាទីជារបាំងការពារភ្លើងព្រៃ។ ទីពីរ ផលប្រយោជន៍ខាងផ្នែកអេកូឡូស៊ីអាចនឹងកែលំអឡើងវិញតាមរយៈការបង្កើតចំការឈើឯកប្រភេទជាលក្ខណៈឆ្លាស់គ្នាជាមួយនឹងចំការឈើឯកប្រភេទផ្សេងៗទៀត។ អត្ថប្រយោជន៍នៃចំការឈើឯកប្រភេទគឺផ្តល់ទិន្នផលឈើខ្ពស់ក្នុងមួយហិកតា។ គេអាចប្រើប្រាស់ប្រភេទឈើដែលមានតំលៃសេដ្ឋកិច្ចខ្ពស់ ហើយតំបន់ទ្រនាប់នឹងដើរតួនាទីជាអ្នកការពារទីជំរាល និង អភិរក្សជីវចំរុះ (David, 2003)។

ចំការឈើឯកប្រភេទដោយមានដំណុះរុក្ខជាតិស្រទាប់ក្រោមៈ ចំការឈើឯកប្រភេទជាច្រើនក្នុងដំណាក់កាលដុះលូតលាស់ បានបង្កើតឱ្យមានដំណុះរុក្ខជាតិស្រទាប់ក្រោម ដែលជាលទ្ធផលនៃការធ្វើអាណានិគមនៃប្រភេទឈើមួយចំនួនពីដំណុះព្រៃធម្មជាតិដែលនៅក្បែរនោះ។ ដំណុះរុក្ខជាតិស្រទាប់ក្រោមទាំងនោះ អាចត្រូវដាំបញ្ចូលដោយប្រើប្រាស់ចំការឈើដែលដាំតំបូងជាគំរបម្លប់។ ក៏ប៉ុន្តែវិធីសាស្ត្រនេះទាមទារឱ្យមានចំណេះដឹង និងការគ្រប់គ្រងខ្ពស់ដើម្បី

ចៀសវាងគំរបម្លប់ លប់បំបាត់ប្រភេទឈើដែលសំខាន់ៗ។

## ១.២ ការអនុវត្តន៍ការរៀបចំដាំដើមឈើ

*សូមប្រើប្រាស់ទំព័របន្ថែម និង ឧបសម្ព័ន្ធនានាដូចខាងក្រោម:*

ឧបសម្ព័ន្ធទី ១: ការជ្រើសរើសប្រភេទឈើ

ឧបសម្ព័ន្ធទី ២: លទ្ធកម្មគ្រាប់ពូជ

ឧបសម្ព័ន្ធទី ៣: ការងារនៅថ្នាលបណ្ដុះកូនឈើ

ឧបសម្ព័ន្ធទី ៤: ការងារនៅចំការដាំឈើ

ឧបសម្ព័ន្ធទី ៥: ការថែរក្សាចំការឈើដាំ

ទំព័របន្ថែមទី ១: ការគណនាបរិមាណគ្រាប់ពូជដែលត្រូវការ

# ២. ចំការឈើពហុប្រភេទ

## ២.១ យុត្តិកម្ម

ការដាំឈើជាទ្រង់ទ្រាយធំ មានលក្ខណៈសមស្របសំរាប់តំបន់ទាំងឡាយណាដែលគ្មានព្រៃឈើ ឬក៏នៅក្នុងតំបន់ដែលព្រៃឈើរេចរិលខ្លាំង មិនអាចអនុញ្ញាតឱ្យអនុវត្តការងារស្តារព្រៃឈើឡើងវិញកើត។

នៅក្នុងករណីខ្លះការបង្កើតចំការឈើដាំដោយប្រើប្រាស់ប្រភេទឈើជាច្រើនប្រភេទមានសារប្រយោជន៍ជាងចំការឈើឯកប្រភេទ។ ការដាំលាយគ្នានូវប្រភេទឈើជាច្រើនប្រភេទ មិនងាយរងនូវការបំផ្លាញពីជំងឺនិងសត្វល្អិតដោយហេតុថាកត្តាធាតុអាកាសប្រចាំតំបន់មានការផ្លាស់ប្តូរ (microclimate changes)។ លើសពីនេះទិន្នផល នៃចំការឈើក៏អាចមានការកើនឡើងប្រសិនបើប្រភេទឈើដែលដាំនោះមានលាយបញ្ចូលនូវអំបូរសិម្ពិកូលដែលមានលទ្ធភាពចាប់យកជីជាតិអាសូតពីបរិយាកាស ហើយម្យ៉ាងទៀតចំការឈើរបៀបនេះធានានូវសន្តិសុខហិរញ្ញវត្ថុ ដោយសារគេអាចប្រមូលផលឈើបានឆាប់ជាង (តាមរយៈការលាយបញ្ចូលនូវប្រភេទដែលឆាប់ផ្តល់ផល) និងជាបន្តបន្ទាប់។ ទោះបីជាវិធីសាស្ត្រនេះ មានលក្ខណៈស្មុគស្មាញក្នុងការបង្កើត និងគ្រប់គ្រងបន្តិចក្តី ប៉ុន្តែភស្តុតាងបានបង្ហាញថាការលាយចំរុះគ្នានូវប្រភេទឈើឱ្យបានសមស្រប នឹងផ្តល់អត្ថប្រយោជន៍ដ៏ធំធេង។

អត្ថប្រយោជន៍ផ្សេងៗទៀតចំពោះការអភិរក្សជីវចំរុះ ការការពារទីជំរាល អាចនឹងសំរេចបាននៅពេលដែលមានសកម្មភាពដាំដើមឈើនៅលើផ្ទៃដីធំធេង។ ការណ៍នេះមានន័យថា ជីវចំរុះក្នុងកំរិតមួយខ្ពស់អាចសំរេចបានតាមរយៈការលាយចំរុះគ្នានៃប្រភេទឈើជាច្រើននៅពេញតំបន់ទេសភាពធម្មជាតិទាំងមូល ឬក៏ការដាំឆ្លាស់គ្នានូវចំការ